សហភាពអឺរ៉ុប

actionaid

# បទបង្ហាញសង្ខេបថ្នាក់គោលនយោបាយក្នុងវិស័យព្រៃឈើ ប្រៀបធៀបជាមួយ គោលការណ៍ណែនាំ ដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការ កាន់កាប់ដី ជលផល និងព្រៃឈើ" ភាពស្របគ្នា គម្លាត បញ្ហាប្រឈមសំខាន់ៗ និងផ្លូវឆ្ពោះទៅមុខ"

*ដោយមេធាវី សេក សោភ័ណ (១៧ ធ្នូ ២០១៨)*

*បទបង្ហាញសង្ខេបថ្នាក់គោលនយោបាយនេះឈរលើមូលដ្ឋាននៃរបាយការណ៍ស្តីពី " ការពិនិត្យឡើងវិញនូវច្បាប់និងក្របខណ្ឌកម្ពុជាលើវិស័យដី ជលផល និងព្រៃឈើ ប្រៀបធៀបជាមួយ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ "ភាពស្របគ្នា គម្លាត បញ្ហាប្រឈម សំខាន់ៗ និងផ្លូវឆ្ពោះទៅមុខ " អង្គការ ActionAid & NGO Forum on Cambodia, ខែវិច្ឆិកា ឆ្នាំ ២០១៨។*

ច្បាប់ស្តីព្រៃឈើជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃកើតដោយធម្មជាតិឬដាំក្តី ហើយក៏ចែងថារដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល និងអនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋាន រួមទាំងសហគមន៍ជនជាតិដើមភាគតិចផងដែរ។ ច្បាប់ស្តីពីតំបន់ការពារ ធម្មជាតិក៏បានធានាសិទ្ធិទាំងនេះដែរ។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋមិនបានចេញវិធានការ ឬចំណាត់ការរដ្ឋបាលបញ្ជាក់ជាលាយលក្ខណ៍អក្សរថា ការធានាសិទ្ធិនោះត្រូវធានាសដោយរបៀបណា តាមយន្តការអ្វីនោះឡើយ។ ក៏ប៉ុន្តែការប្រតិបត្តិច្បាប់រហូតមកដល់ពេលនេះ រដ្ឋបាលចេញបទដ្ឋានសម្រាប់បង្កើតសហគមន៍ព្រៃឈើ និងសហគមន៍ការពារធនធានធម្មជាតិ។ ជាលទ្ធផលមានសហគមន៍ព្រៃឈើ និងសហគមន៍ការពារតំបន់ការពារធម្មជាតិជាច្រើនត្រូវបាន និងកំពុង ដំណើរការ។

គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ លើការកាន់កាប់ដី ជលផល និងព្រៃឈើ ហៅកាត់ខ្លីថា វីជីជីធី (VGGT) កំណត់អំពី "សិទ្ធិធម្មានុរូបនៃការកាន់កាប់ព្រៃឈើ" ថានៅ ពេលធ្វើច្បាប់ គោលនយោបាយ លិខិតបទដ្ឋានជាតិ រដ្ឋត្រូវគោរពដោយ ៖

១) កំ ណត់អត្តសញ្ញាណអ្នកកាន់កាប់ធម្មានុរូបដោយធ្វើការកត់ត្រាក្នុងបញ្ជី

២) ការពារសិទ្ធិធម្មានុរូបរបស់ អ្នកកាន់កាប់សិទ្ធិ

៣) សម្របសម្រួលឲ្យអ្នកកាន់កាប់ធម្មានុរូប ដោយមិនមានការបន្ទុចបង្អាក់

៤) ក្នុងករណីមានការបំពានសិទ្ធិធម្មានុរូបលើព្រៃឈើ នោះរដ្ឋមានយន្តការប្រកបដោយប្រសិទ្ធភាពឲ្យ ម្ចាស់សិទ្ធិធម្មានុរូបរកយុត្តិធម៌តាមច្បាប់ រួចពីការគម្រាមកំហែង ឬអំពើពុករលួយទាំងឡាយ។

ក្របខណ្ឌគតិយុត្តជាធរមានមិនចែងច្បាស់អំពី "សិទ្ធិធម្មានុរូបលើព្រៃឈើ"នៃអ្នកកាន់កាប់សិទ្ធិប្រើប្រាស់ ដូចមានក្នុង VGGT និងមិនមានការចុះបញ្ជីសិទ្ធិប្រើប្រាស់ ឬសិទ្ធិអាស្រ័យផលលើផល និងអនុផលព្រៃឈើទេ ហើយក៏មិនមានលិខិតសម្គាល់អ្វីមួយចេញឲ្យអ្នកកាន់កាប់សិទ្ធិធម្មានុរូបទេ។ ប្រសិនបើសិទ្ធិប្រើប្រាស់នោះត្រូវ បានប៉ះពាល់ ឬដកហូត ឬបំពាន ក៏មិនឃើញមានយន្តការណាសម្រាប់ម្ចាស់សិទ្ធិប្រើប្រាស់ទៅរកដំណោះ ស្រាយរឿងសិទ្ធិធម្មានុរូបលើព្រៃឈើដូចចែងក្នុង VGGT ក៏ទេដែរ គឺមានតែកម្មសិទ្ធិដី និងសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិប៉ុណ្ណោះ។ មានតែអាជ្ញាធរមូលដ្ឋានដូចជាមេភូមិ អនុភូមិ ឃុំ ស្រុក ។ល។ ដែលជារួមសមត្ថភាពជំនាញ និងធនធានថវិកាក្នុងការដោះស្រាយជាបញ្ហាចម្បង និងដោយសារមន្ត្រីមានការងារ ស្មុលរបស់ខ្លួនដែរ។ នៅក្នុង រឿងព្រៃឈើ រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ត្រូវបានប្រគល់អាណត្តិ និងតួនាទីក្នុងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ចំណែកតំបន់ការពារបរិស្ថាន ក៏មានព្រៃឈើដែរ តែស្ថិតក្រោមអាណត្តិ និងតួនាទីរបស់ក្រសួងបរិស្ថាន ដែលមានច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

នៅពេលមានការតតាំងគ្នារវាងភ្នាក់ងាររដ្ឋ ឬក្រុមហ៊ុនដែលបានចុះកិច្ចសន្យាជាមួយរដ្ឋ និងអ្នកធ្លាប់បានប្រើប្រាស់ផល អនុផលព្រៃតាមប្រពៃណី ទំនៀមទម្លាប់ដូចបាន ធានដោយច្បាប់ស្តីពីព្រៃឈើនោះបញ្ហាគន្លឹះគឺថា តើសិទ្ធិប្រើប្រាស់របស់គាត់ជាសហគមន៍ ឬជាបុគ្គលលើព្រៃឈើដែលធានាដោយច្បាប់ត្រូវដោះស្រាយយ៉ាងណា? មានអ្វីសម្គាល់សិទ្ធិនោះ? តាមយន្តការអ្វី? ជារួមដើម្បីរដ្ឋក្លាយជាកម្មសិទ្ធិករលើព្រៃឈើ ក៏ត្រូវមានប័ណ្ណកម្មសិទ្ធិ លើដីព្រៃឈើទាំងអស់នោះដែរ មុននឹងប្រគល់សិទ្ធិរបស់រដ្ឋទៅឲ្យក្រុមហ៊ុនអភិវឌ្ឍ ក្នុងរយៈពេលកំណត់មួយ។ នៅក្នុង VGGT ស្នើថាពលរដ្ឋក្នុងមូលដ្ឋាននៅក្នុង ឬជុំវិញតំបន់ព្រៃឈើក៏មានសិទ្ធិធម្មានុរូបលើព្រៃឈើនោះដែរ ហេតុនេះរដ្ឋគួរមានយន្តការធ្វើអត្តសញ្ញាណម្ចាស់សិទ្ធិ កត់ត្រាម្ចាស់សិទ្ធិ ការពារ និងសម្រួលដល់ម្ចាស់សិទ្ធិធម្មានុ រូបទាំងនោះ។

នៅក្នុងក្របខណ្ឌគតិយុត្តជាធរមានអំពីអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ រដ្ឋគួរៈ

១- ពិចារណាពីការកំណត់អត្តសញ្ញាណពលរដ្ឋ ដែលបានប្រើប្រាស់ផល និង/ឬអនុផលព្រៃឈើ រួមទាំង សហគមន៍ជនជាតិដើមភាគតិចផងៗ ការកំណត់អត្តសញ្ញាណ និងការកត់ត្រាគួរផ្តោតលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើផល និងអនុផល

ព្រៃឈើ ដែលប្រើប្រាស់ជាប្រពៃណី និងការទទួលស្គាល់ថា ជាការកាន់កាប់ធម្មានុរូប និងជាមុខរបរចិញ្ចឹមជីវិតជាប្រពៃណី។ ការកំណត់អត្តសញ្ញាណ ការកត់ត្រាធនធានព្រៃឈើ ក៏គួរពិចារណាជាប្រពន្ធ័ ដែលជាមូលដ្ឋានសិទ្ធិសម្រាប់ការទទួលស្គាល់ ការពារ និងសម្របសម្រួលឲ្យពលរដ្ឋនោះអនុវត្តសិទ្ធិរបស់គេដោយទទួលខុសត្រូវ និងបង្កភាពងាយស្រួលនៅពេលមានការដកហូតសិទ្ធិធម្មានុរូបនោះ ឬអនុវត្តសិទ្ធិហួសក្របខ័ណ្ឌប្រពៃ ណីទំនៀមទម្លាប់ដែរ។ ឧទាហរណ៍១ ថា ដើមច្បោះយកជ័រទឹក ដែលជាក់ស្តែងនៅក្នុងព្រៃ តែពលរដ្ឋ គាត់បានកាន់កាប់ដើមជ័រនោះជាយូរហើយ អាស្រ័យផលពីដើមច្បោះនោះ ហើយអ្នក ជិតខាង និងអ្នកភូមិដឹងឮ តែសិទ្ធិនេះមិនត្រូវបានចុះបញ្ជីតាមគោលការណ៍អភិបាលកិច្ចទេ។ ឧទាហរណ៍២ ថាព្រៃឈើ ដែលសហគមន៍តែងតែចូលរកវល្លិ ផ្តៅ ផ្សិត និងពឹងផ្អែកជីវភាពរស់នៅប្រចាំថ្ងៃ មានទំនាក់ទំនង ជីវិតជាមួយពលរដ្ឋក្នុង តំបន់នោះ ហើយសិទ្ធិជាប្រពៃណីលើព្រៃនេះត្រូវបានច្បាប់ធានា។ តើត្រូវ ធានារបៀបណា? តាមយន្តការអ្វី? និងពេលមាន ការដកហូតសិទ្ធិនោះពីពលរដ្ឋនោះ មានយន្តការអ្វីដោះស្រាយ? ឧទាហរណ៍នេះបង្ហាញថា ការកាន់កាប់ធម្មានុរូបលើព្រៃឈើ ទាំងនោះមិនមែនជា កម្មសិទ្ធិទេ ក៏ប៉ុន្តែពលរដ្ឋមានសិទ្ធិធម្មានុរូបក្នុងន័យរបស់គោលការណ៍ VGGT ដែលក្នុងស្មារតីច្បាប់ កម្ពុជាទទួលស្គាល់សិទ្ធិប្រើប្រាស់ជាប្រពៃណី។

២- មានសេចក្តីណែនាំ ឬ ប្រកាសណាមួយដើម្បីឲ្យអាជ្ញាធរមូលដ្ឋានបញ្ជាក់ ឬចេញលិខិតបញ្ជាក់ សិទ្ធិធម្មានុរូបលើព្រៃឈើ (ផល អនុផល) សម្រាប់គ្រួសារនីមួយៗ បន្ថែមលើកិច្ចការសហគមន៍ព្រៃ ឈើ ដែលបានចុះកិច្ចព្រមព្រៀងរួចហើយ ឬមិនទាន់បានចុះកិច្ចព្រមព្រៀង។

៣- មានយន្តការពិគ្រោះយោបល់ និងចូលរួមសម្រេចចិត្ត ដែលធានាថា ពលរដ្ឋជាម្ចាស់សិទ្ធិធម្មានុរូប លើព្រៃឈើបានចូលរួមដោយសេរី មានព័ត៌មាន និងយល់ស្របជាមុន មុននឹងរដ្ឋសម្រេចប្រគល់សិទ្ធិ របស់រដ្ឋលើព្រៃឈើ និងដីព្រៃឈើឲ្យក្រុមហ៊ុនវិនិយោគ។

៤- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងតួអង្គសំខាន់ៗឲ្យយល់ច្បាស់អំពីសិទ្ធិធម្មានុរូបលើព្រៃឈើ ពិសេសសហគមន៍ជនជាតិដើមភាគតិច និងស្ត្រី ដែលមានទំនៀមទម្លាប់ និងមុខរបរពឹងផ្អែកលើអនុផលព្រៃឈើ ។

៥- អប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីនីតិវិធីដាក់ពាក្យបណ្តឹង ការប្រមូលភស្តុតាង នៅពេលមាន ការរំលោភសិទ្ធិធម្មានុរូបលើព្រៃឈើ ក្នុងគោលការណ៍អភិបាលកិច្ចកើតឡើង។

៦- ពិភាក្សាក្នុងក្របខណ្ឌថ្នាក់ជាតិលើការកំណត់យកគោលការណ៍ស្នូលរបស់ វីជីជីធី ជាមូលដ្ឋាន។

គាំទ្រមូលនិធិដោយ

សហភាពអឺរ៉ុប

សហការរៀបចំដោយ៖

Cambodian Center for Human Rights

Building Community Voices

The NGO Forum on Cambodia

C.W.D.C.C

actionaid